ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
№ ៥៧៦ ឧរថ.អស.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០០៤

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការសហប្រតិបត្តិការ កម្ពុជា_ឡាវ_មីយ៉ាន់ម៉ា_ថៃ

- បានឃើញព្រះរាជក្រឹតលេខ ន.ស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹតលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាសលេខ ៩៧៥ ឧរថ បល.ប្រក ចុះថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ២០០០
- តាមស្មារតីនៃកិច្ចប្រជុំថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០០៣ ស្តីពីការរៀបចំគ្រប់គ្រងកិច្ចសហប្រតិបត្តិការបួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ ។

## សំរេច

**ប្រការ ១** : បង្កើតគណៈកម្មាធិការមួយរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដែលមានសមាសភាពដូចខាងក្រោម :

- ឯកឧត្តម **ខ្លូត រ៉ាន់ឌី** រដ្ឋលេខាធិការ ជាប្រធាន
- ឯកឧត្តម **ខួន នៅ** អគ្គនាយកឧស្សាហកម្ម ជាអនុប្រធាន
- ឯកឧត្តម **សុទ ឌីគុណា** អគ្គនាយកធនធានរ៉ែ ជាអនុប្រធាន
- លោក **ឌុន លាន** អគ្គនាយករងថាមពល ជាអនុប្រធាន

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ :(៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣. ៤២៨២៦៣
45 Preah Norodom Boulevard , Khan Daun Penh, Phnom Penh , Phone : 855. 23 . 211141 Fax : 855 23 428263

- លោក **ស៊ុន សុណា** ប្រធាននាយកដ្ឋាន ជាសមាជិកអចិន្ត្រៃយ៍
- លោក **ស៊ឹម ណារ៉ា** ប្រធានការិយាល័យ ជាសមាជិក

**ប្រការ ២** : គណៈកម្មាធិការ មានអនុគណៈកម្មាធិការចំនួន ៣ ជាជំនួយការ :

ក. អនុគណៈកម្មាធិការឧស្សាហកម្ម មានសមាសភាព :

- ឯកឧត្តម **ខួន នៅ** អគ្គនាយកឧស្សាហកម្ម ប្រធាន
- លោក **កែវ សុវត្ថិ** ប្រធាននាយកដ្ឋាន សមាជិក
- លោក **ហូ ភាដឹប** ប្រធាននាយកដ្ឋាន សមាជិក
- លោក **ពឹង ស៊ីវឡាយ** ប្រធាននាយកដ្ឋាន សមាជិក
- លោក **សាត សមុទ្រ** ប្រធាននាយកដ្ឋាន សមាជិក
- លោក **ជា តារា** អនុប្រធាននាយកដ្ឋាន សមាជិក
- លោក **នួវ ថារ៉ា** អនុប្រធាននាយកដ្ឋាន សមាជិក

ខ. អនុគណៈកម្មការភូគព្ភសាស្ត្រ រ៉ែ មានសមាសភាព :

- ឯកឧត្តម **សុខ ជីគុណា** អគ្គនាយកធនធានរ៉ែ ប្រធាន
- លោក **សៀង ស៊ីថាង** ប្រធាននាយកដ្ឋាន សមាជិក
- លោក **ថ្វះ វិចិត្រ** អនុប្រធាននាយកដ្ឋាន សមាជិក
- លោក **យស់ មុនីរ៉ាត់** អនុប្រធាននាយកដ្ឋាន សមាជិក
- លោក **ម៉ក់ សុភត្រា** អនុប្រធាននាយកដ្ឋាន សមាជិក

គ. អនុគណៈកម្មការថាមពល មានសមាសភាព :

- លោក **នុន លាង** អគ្គនាយករង ប្រធាន
- លោក **ប៊ុន ណារិទ្ធ** ប្រធាននាយកដ្ឋាន សមាជិក
- លោក **ទិចន៍រ ហ្សុណា** អនុប្រធាននាយកដ្ឋាន សមាជិក
- លោក **តូច សុវណ្ណា** ប្រធានការិយាល័យ សមាជិក
- លោក **ហេង គុណលាង** ប្រធានការិយាល័យ សមាជិក
- លោក **ខួន ចាន់វ៉ាន់ដា** ប្រធានការិយាល័យ សមាជិក

**ប្រការ ៣** : គណៈកម្មាធិការនេះ ទទួលបន្ទុកលើការងារសហប្រតិបត្តិការបួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ ទៅតាមស្មារតីនៃសេចក្តីប្រកាសរួម ស្តីពីកិច្ចសហប្រតិបត្តិការបួនប្រទេស ហើយមានភារកិច្ចដូចខាងក្រោម :

- លើកគំរោង និង ចរចាដោយផ្ទាល់ រវាងស្ថាប័នពាក់ព័ន្ធក្នុងយុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការបួនប្រទេស ដើម្បីជំរុញអនុវត្តផែនការសកម្មភាពបាហ្គាន ។
- តាមដាន និង ត្រួតពិនិត្យ រាល់ការអនុវត្តន៍គំរោងសហប្រតិបត្តិការបួនប្រទេស កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ ។
- ចាត់ចែង រៀបចំកិច្ចប្រជុំ ក្នុង និង ក្រៅប្រទេស ។
- ធ្វើរបាយការណ៍អំពីដំណើរការ នៃការអនុវត្តន៍យុទ្ធសាស្ត្រ នៃកិច្ចសហប្រតិបត្តិការកម្ពុជា ឡាវ មីយ៉ាន់ម៉ា និង ថៃ ជូនថ្នាក់ដឹកនាំក្រសួង ។

**ប្រការ ៤** : អនុគណៈកម្មាធិការ មានភារកិច្ចចរចាជាមួយក្រុមការងារ នៃប្រទេសដៃគូរ និង អនុវត្តគំរោងទាំងឡាយក្នុងកិច្ចសហប្រតិបត្តិការបួនប្រទេស និង ភារកិច្ចចាំបាច់នានា ដូចក្នុងប្រការ ៣ តាមការកំណត់របស់ប្រធានគណៈកម្មាធិការ តាម វិស័យរៀងៗ ខ្លួន ។

**<u>ប្រការ ៥</u>** : សមាជិកទាំងអស់នៃគណៈកម្មាធិការ និងអនុគណៈកម្មាធិការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ <u>៦</u>** : អគ្គនាយកដ្ឋានឧស្សាហកម្ម អគ្គនាយកដ្ឋានធនធានរ៉ែ និង អគ្គនាយកដ្ឋានថាមពល នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ខុទ្ទកាល័យរដ្ឋមន្ត្រី និង ឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ត្រូវអនុវត្តតាមសមត្ថកិច្ចរៀងៗខ្លួន តាមប្រកាសនេះ ។

**<u>ប្រការ ៧</u>** : រាល់ប្រកាស ឬ កំណត់ចាត់ការទាំងឡាយពីមុន ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**<u>ប្រការ ៨</u>** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

**ស៊ុយ សែម**

<u>កន្លែងទទួល</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ